00323157

Declassified to Public
06 September 2012

D84/3

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 05 / 05 / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

បណ្ណាល័យអង្គការសហប្រជាជាតិ
ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៥
ឯកសារUN/SA

**មហាសន្និបាតអង្គការសហប្រជាជាតិ**

ចែកចាយទូទៅ
A/10061
ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៥
អង់គ្លេសភាសាដើម: ចិន/អង់គ្លេស/បារាំង

---

សម័យប្រជុំលើកទីសាមសិប
ប្រការ២៩នៃបញ្ជីដំបូង*

**ការទទួលយកមកវិញនូវសិទ្ធិស្របច្បាប់របស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា នៅក្នុងអង្គការសហប្រជាជាតិ**

<u>លិខិតចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ ពីតំណាងអចិន្ត្រៃយ៍របស់ចិនប្រចាំអង្គការសហប្រជាជាតិជូនចំពោះអគ្គលេខាធិការ</u>

ឯកឧត្តម លោក សារិន ឆាក (Sarin Chhak) រដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានផ្ញើសារទូរលេខជូនឯកឧត្តមកាលពីថ្ងៃទី១៨ ខែ មីនា ដោយស្នើសុំថា សេចក្តីថ្លែងការណ៍ដែលចេញដោយសមាជជាតិលើកទី២របស់កម្ពុជា ដែលបានធ្វើនៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ត្រូវចែកចាយទៅគ្រប់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់។ គណៈប្រតិភូចិន គាំទ្រសំណើនេះ និងសូមស្នើសុំឯកឧត្តមមេត្តារៀបចំចែកចាយសារទូរលេខនេះ និងសេចក្តីថ្លែងការណ៍ ជាឯកសារផ្លូវការរបស់មហាសន្និបាត។

(ហត្ថលេខា) HUANG Hua
តំណាងអចិន្ត្រៃយ៍នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំអង្គការសហប្រជាជាតិ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

Original EN: 00179652-00179655

ក្នុងឱកាសនេះ តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា (FAPLNK) សមាជជាតិអំពាវនាវដល់មន្ត្រី និងយោធា នាយនគរបាល និងនគរបាល សមាជិកអង្គភាពស្វ័យការពារ មន្ត្រី អ្នកនយោបាយ និងអ្នកមុខអ្នកការផ្សេងៗទៀតដែលរស់នៅក្នុងតំបន់ក្រោមការគ្រប់គ្រងជាបណ្ដោះអាសន្នរបស់ខ្មាំង នៅមានពេលត្រូវបោះបង់ជនក្បត់ទាំង៧នាក់នៅឡើយ ដែលនឹងបាត់បង់ក្នុងពេលឆាប់ៗនេះ ។ សមាជជាតិជម្រុញឱ្យពួកគេចូលរួមជាមួយប្រជាជននៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងតំបន់ផ្សេងៗទៀតក្រោមការគ្រប់គ្រងជាបណ្ដោះអាសន្នរបស់ខ្មាំង ដើម្បីតស៊ូប្រឆាំងពួកក្បត់ ប្រើប្រាស់គ្រប់មធ្យោបាយដើម្បីកម្ទេចអង្គការពួកក្បត់ទាំងនេះ ទីតាំងយោធា កន្លែងទុកគ្រាប់រំសេវ ស្បៀងអាហារ និងប្រេងរបស់ពួកគេ បែរអាវុធរបស់ខ្លួនប្រឆាំងនឹងពួកក្បត់ ខិតខំប្រឹងប្រែងបន្ថែមទៀត និងចូលរួមចំណែករំដោះជាតិ និងប្រជាជន។

<u>ចំណុចទី២.</u> ចំពោះចក្រពត្តិអាមេរិក ដែលកំពុងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា និងកំពុងវាយប្រហារជាចំហរដល់កិច្ចការផ្ទៃក្នុងរបស់កម្ពុជា ដោយអនុវត្តនយោបាយរបស់ខ្លួន "Khmerization" នៃសង្គ្រាម ដែលបានបណ្ដាលឱ្យស្លាប់រាប់មិនអស់ ហិនហោច និងរងទុក្ខរាប់មិនបាន សមាជជាតិ តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា សូមប្រកាសជាថ្មីម្ដងទៀតដូចខាងក្រោមនេះ:

ជាតិ និងប្រជាជនកម្ពុជា ដែលដឹកនាំដោយរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា កំពុងតស៊ូបំបាត់រាល់ការជ្រៀតជ្រែកទាំងអស់ ការឈ្លានពានដោយផ្ទាល់ និងដោយប្រយោលរបស់ចក្រពត្តិអាមេរិកប្រឆាំងនឹងកម្ពុជា និងដើម្បីឱ្យដកទីប្រឹក្សាយោធា ទីប្រឹក្សាសន្តិភាវកម្ម និងភ្នាក់ងាររបស់ពួកគេដែលជួយដល់ពួកក្បត់ក្រុងភ្នំពេញទាំងអស់របស់ពួកគេ ចេញពីកម្ពុជា។ នៅក្នុងការតស៊ូនេះ ជាតិ និងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា មិនមានបំណងជ្រៀតជ្រែក ឬឈ្លានពានប្រឆាំងនឹងសហរដ្ឋអាមេរិក ជាតិ និងប្រជាជនអាមេរិក ឬប្រឆាំងនឹងប្រទេស ឬប្រជាជន

ណាផ្សេង ទាំងឆ្ងាយទាំងជិតទេ។ យើងកំពុងតស៊ូតែឯងដើម្បីសេរីភាព ឯករាជ្យ និងកិត្យានុភាពជាតិរបស់យើង។

<u>ចំណុចទី៣.</u> សមាជជាតិ តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា សូមអះអាងបញ្ជាក់សារជាថ្មីជាឱឡារិកថា នយោបាយក្នុងប្រទេស និងក្រៅប្រទេសរបស់ខ្លួនគឺមានដូចខាងក្រោម:

នៅក្នុងប្រទេស រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា សូមទទួលខុសត្រូវជោគវាសប្រទេសជាតិ។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាប្រកាន់ខ្ជាប់នូវគោលនយោបាយបង្រួបបង្រួមជាតិនិងប្រជាជនទាំងមូលទូលំទូលាយ មិនគិតពីវណ្ណៈសង្គម និន្នាការនយោបាយ ជំនឿសាសនា ឬអតីតកាលរបស់ខ្លួន លើកលែងតែពួកក្បត់៧នាក់ លន់ នល់ សិរីមតៈ សឺន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និងស៊ុស្តែន ហ្វែណង់ដេស។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាកំពុងកសាងកម្ពុជារុងរឿង ដែលគ្រប់ៗគ្នានឹងមានអាហារគ្រប់គ្រាន់ សំលៀកបំពាក់និងលំនៅដ្ឋានសមរម្យ ហើយនឹងមានការថែរក្សាសុខភាពនិងការសិក្សាអប់រំ។

ក្រៅប្រទេស រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា អនុវត្តនយោបាយអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា នឹងមិនទទួលយកមូលដ្ឋានយោធាឈ្លានពាននៅក្នុងទឹកដីកម្ពុជាទេ។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ប្រកាន់ខ្ជាប់យ៉ាងរឹងមាំនូវគោលការណ៍ទាំង៥នៃការរួមរស់ជាមួយគ្នាដោយសន្តិភាព រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា បង្កើតទំនាក់ទំនងជាមួយបណ្តាប្រទេសទាំងអស់ទាំងជិតទាំងឆ្ងាយ មិនប្រកាន់របបនយោបាយ និងសង្គម ដែលបានថែងថា បណ្តាប្រទេសទាំងនេះគោរពគោលការណ៍ស្មើភាព គោរពគ្នាទៅវិញទៅមក និងផលប្រយោជន៍ទៅវិញទៅមក មិនឈ្លានពាន

គ្នា និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ។ ជាតិនិងប្រជាជនកម្ពុជា នឹងទទួលយករាល់ទម្រង់ជំនួយទាំងអស់ពីគ្រប់បណ្ដាប្រទេស ដែលគ្មានលក្ខខណ្ឌភ្ជាប់មកជាមួយ។

<u>ចំណុចទី៤.</u> សមាជជាតិ តាងនាមឱ្យរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា សូមអំពាវនាវដល់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ ទីរួមខេត្តក្រោមការគ្រប់គ្រង់ជាបណ្ដោះអាសន្នរបស់ខ្មាំង ព្រះសង្ឃ គ្រហស្ថ កម្មករគ្រប់ប្រភេទ សិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ ដើម្បីងើបឈរឡើងរួបរួមគ្នាធ្វើការតស៊ូផ្ដួលរំលំពួកក្បត់។ ក្រោមការវាយប្រហារយ៉ាងខ្លាំងក្លាពីគ្រប់ទិសដោយ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ពួកក្បត់ស្ដន់ស្ដោ កំពុងទទួលរងការឈឺចាប់ដល់ស្លាប់ និងក្នុងពេលឆាប់ៗជាដង្ហើមចុងក្រោយរបស់ពួកគេ។

សូមបុព្វជិតព្រះពុទ្ធសាសនា ជនរួមជាតិ ងើបឈរ រួបរួមគ្នា វាយប្រហារ និងតស៊ូចំពោះខ្មាំងនៅខាងក្នុងតាមគ្រប់មធ្យោបាយ ដោយប្រមូលផ្ដុំគ្នា ធ្វើបាតុកម្ម កុបកម្ម ដោយជំទាស់ទៅនឹងកំណែនទាហាន ប្រឆាំងនឹងការអត់អាហារ ដោយការវាយប្រហារការស្តុកអង្ករ និងស្បៀងអាហាររបស់ពួកក្បត់ និងដោយធ្វើការបះបោរ។ សូមឱ្យពួកគេងើបឈរឡើង ដណ្ដើមអាវុធខ្មាំងសត្រូវ និងបំផ្លាញវា បំផ្លាញកន្លែងរដ្ឋបាល ស្ថានីយ៍វិទ្យុ ប៉ុស្តិ៍កងរាជអាវុធហត្ថ ជំរំ និងទីបញ្ជាការពួកក្បត់។ សូមឱ្យពួកគេបំផ្លាញទីស្នាក់ការកណ្ដាលនៃវិទ្យាស្ថាននយោបាយ និងសេដ្ឋកិច្ចរបស់ខ្មាំងសត្រូវ និងទីតាំងឃោធារបស់វា ។ បើសិនជាចាំបាច់ សូមឱ្យបុព្វជិតព្រះពុទ្ធសាសនា និងជនរួមជាតិឆ្លងកាត់តំបន់រំដោះ។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងអង្គការរណសិរ្សបង្រួបបង្រួមជាតិកម្ពុជាទាំងអស់គ្រប់ជាន់ថ្នាក់ស្វាគមន៍ពួកគេយ៉ាងកក់ក្ដៅ និងជួយពួកគេឱ្យអស់ពីចិត្តទាំងស្មារតីនិងសម្ភារៈនៅក្នុងជីវិតថ្មីក្នុងតំបន់រំដោះ។

<u>ចំណុចទី៥.</u> នៅពេលរបបផុតរលត់របស់ពួកក្បត់ភ្នំពេញដួលរលំ និងជាពិសេសនៅពេលប្រាក់រៀលរបស់ពួកក្បត់មិនចាយនៅក្នុងប្រទេស ឬក្រៅប្រទេស សមាជជាតិប្រកាសថា ដោយសារប្រាក់រៀលរបស់ពួកក្បត់ភ្នំពេញនឹងមិនប្រើប្រាស់តទៅទៀតទេ ប្រាក់រៀលថ្មីដែលបោះពុម្ពដោយរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានឹងត្រូវដាក់ឱ្យធ្វើចរាចរ។

រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងទីភ្នាក់ងារធនាគារមានសមត្ថភាពជាបណ្តើរៗនឹងអនុវត្ត គោលការណ៍ និងបែបបទសម្រាប់ចរាចរប្រាក់រៀលថ្មីនេះ ដោយយោងទៅតាមស្ថានភាពជាក់ស្តែង។

មកដល់ពេលនេះ នៅក្នុងតំបន់រំដោះ មិនមានឧបសគ្គរាំងដំណើរការរីកចម្រើនសេដ្ឋកិច្ច ដ៏រលូន ហិរញ្ញវត្ថុ និងសង្គ្រាមរំដោះជាតិ ឬរំខានជីវិតរបស់ប្រជាជនទេ ចំពោះការអនុវត្តនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលផ្អែកលើប្រព័ន្ធប្តូរទំនិញ ដែលជាបណ្តើរៗអាចលែងប្រើប្រាស់ប្រាក់រៀលខ្មាំង។ នៅក្នុងឆ្នាំ១៩៧៣ ប្រាក់រៀលខ្មាំងត្រូវបានប្រើប្រាស់តែ១៥ភាគរយប៉ុណ្ណោះនៅក្នុងកិច្ចការជំនួញក្នុងតំបន់រំដោះ។ អំឡុងឆ្នាំ១៩៧៤ ភាគរយនោះបានថយចុះ៥ភាគរយ និងអំឡុងខែមករា ឆ្នាំ១៩៧៥ មកដល់ត្រឹម០,៥ភាគរយ និងអំឡុងពាក់កណ្តាលខែកុម្ភៈ ការប្រើប្រាស់ប្រាក់រៀលខ្មាំងត្រូវហាមឃាត់ទាំងស្រុង។ នៅក្នុងពេលអនាគត ប្រព័ន្ធប្តូរទំនិញនឹងបន្តរហូត រីឯប្រាក់រៀលថ្មីដែលបោះពុម្ពដោយ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា នឹងត្រូវដាក់ឱ្យធ្វើចរាចរជាបណ្តើរ។ ដូច្នេះ លទ្ធភាពថ្មីនឹងបើកចំហរសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុបម្រើប្រជាជន និងសង្គ្រាមរំដោះជាតិ។

រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងអង្គការរណសិរ្សបង្រួបបង្រួមជាតិកម្ពុជាទាំងអស់គ្រប់ជាន់ថ្នាក់អនុវត្តតាមគោលនយោបាយត្រឹមត្រូវនៃជំនួយនិងការគាំទ្រជនរួមជាតិរបស់យើងទាំងអស់គ្រប់វណ្ណៈសង្គម មន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់ នាយទាហាន និងពលយោធា និងសមាជិកកងកម្លាំងប៉ូលិសទាំងអស់ដែលជាបណ្តើរៗបានបោះបង់ខ្មាំងមករកតំបន់រំដោះ។ គេបានផ្តល់ឱ្យពួកគេនូវការផ្គត់ផ្គង់ និងមធ្យោបាយផលិតគ្រប់គ្រាន់ ដែលអាចឱ្យពួកគេរស់នៅសមរម្យដោយមិនចាំបាច់ប្រើប្រាស់ប្រាក់រៀលខ្មាំង។

ជនរួមជាតិគ្រប់វណ្ណៈសង្គមទាំងអស់ដែលរស់នៅក្នុងទីក្រុងភ្នំពេញ នៅក្នុងទីរួមខេត្តដែលនៅសល់មួយចំនួនតូចដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មាំងជាបណ្តោះអាសន្ន មន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់ នាយទាហាន និងពលយោធាគ្រប់ថ្នាក់ នាយប៉ូលិស និងប៉ូលិសគ្រប់ថ្នាក់ដែលកំពុងត្រៀមបោះបង់ពួកក្បត់ដើម្បីចូលរួមតំបន់រំដោះ ហើយរណសិរ្សបង្រួបបង្រួមជាតិកម្ពុជាមិនចាំបាច់បារម្ភអំពីមធ្យោបាយដែលមានស្រាប់ និងការងារ ដែលនឹងត្រូវធានាទាំងស្រុង។

A/10061
អង់គ្លេស
ឧបសម្ព័ន្ធ
ទំព័រ ៤

<u>ចំណុចទី៦.</u> សមាជជាតិ តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និង កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា សូមអំពាវនាវជាថ្មីម្តងទៀតដល់ស្ថានទូត និងទីភ្នាក់ងារបរទេសទាំងអស់ដែលប្រចាំការនៅក្នុងរបបពួកក្បត់ សូមដកបុគ្គលិក និងគ្រួសាររបស់ពួកគេ កុំបង្អង់ពីទីក្រុងភ្នំពេញ និងរបបក្រោមការត្រួតត្រារបស់ខ្មាំងជាបណ្តោះអាសន្នដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមាន។ រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបដិសេធមិនទទួលខុសត្រូវចំពោះគ្រោះថ្នាក់បែបនេះទេ។

<u>ចំណុចទី៧.</u> តាងនាមឱ្យជាតិនិងប្រជាជនកម្ពុជា តាងនាមឱ្យរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ដោយមានសម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ជាព្រះប្រធាន  តាងនាមឱ្យរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាដោយមានសម្តេចប៉ែន នុត ជានាយករដ្ឋមន្ត្រី និងតាងនាមឱ្យកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា  សមាជជាតិ ជាថ្មីម្តងទៀតសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅដល់ប្រជាជននិងបណ្តាប្រទេសជាបងប្អូន ទាំងជិតឬឆ្ងាយ ប្រជាជនអាមេរិក យុវជនអាមេរិក និងជនជាតិអាមេរិកល្បីៗដែលស្រលាញ់សន្តិភាព និងយុត្តិធម៌ សម្រាប់ការតស៊ូរំដោះជាតិនិងប្រជាជន។ សមាជជាតិ សូមអំពាវនាវដល់ពួកគេឱ្យបន្តជំនួញនិងគាំទ្រ និងជាពិសេសរារាំងឧបាយកលនិងទង្វើជ្រៀតជ្រែក និងឈ្លានពានកម្ពុជាដោយរដ្ឋបាលលោក Ford-Kissinger ដូច្នេះសូមទុកឱ្យជាតិ និងប្រជាជនកម្ពុជាដោះស្រាយបញ្ហាផ្ទាល់ខ្លួនដោយខ្លួនឯង ដោយគ្មានការជ្រៀតជ្រែកណាមួយពីបរទេស។

<u>ចំណុចទី៨.</u> តាងនាមឱ្យរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា សមាជជាតិ សូមអំពាវនាវដល់ប្រជាជនកម្ពុជាទាំងអស់ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាទាំងបីប្រភេទ ទាំងនៅសមរភូមិមុខ និងនៅសមរភូមិក្រោយ ពង្រឹងស្មារតីប្រយុទ្ធរបស់ខ្លួន និងវាយប្រហារខ្មាំងមិនឈប់ឈរដើម្បីរំដោះជាតិនិងប្រជាជនរបស់យើងជានិរន្តរ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត បើសិនជាលោកផ្សព្វផ្សាយសេចក្តីថ្លែងការណ៍នេះទៅគ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ជាឯកសារផ្លូវការ។

សារិន ឆាក (Sarin Chhak)
រដ្ឋមន្ត្រីក្រសួងការបរទេសនៃ
រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា